**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ០៣៧ ១ ស.ខ.ល

# សេចក្តីប្រកាសព័ត៌មាន

យោងតាមបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាយប់ ថ្ងៃសុក្រ ទី២១ ខែមករា ឆ្នាំ២០២២ បានចេញសារពិសេសណែនាំឲ្យកែប្រែលក្ខខណ្ឌព្យាបាលអ្នកជំងឺកូវីដ-១៩ បំប្លែងថ្មី ប្រភេទអូមីក្រុង (Omicron) បន្ទាប់ពីឃើញស្ថានភាពជំងឺនេះ មិនមានសភាពធ្ងន់ធ្ងរ។

ក្រសួងសុខាភិបាល មានកិត្តិយសសូមជម្រាបជូនសាធារណជនឱ្យបានជ្រាបពីការធ្វើបច្ចុប្បន្នភាពនីតិវិធីសម្រាប់បង្ការ និងទប់ស្កាត់ការចម្លង និងរីករាលដាលនៃវីរុសកូវីដ-១៩ បំប្លែងថ្មី ប្រភេទអូមីក្រុង (Omicron) សម្រាប់អ្នកដំណើរចូលប្រទេសកម្ពុជាទាំងអស់៖

- ក្នុងករណីទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ អវិជ្ជមាន ត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរធម្មតា។ សម្រាប់អ្នកដំណើរដែលពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ត្រូវធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ដើម្បីតាមដាន និងត្រួតពិនិត្យសុខភាព។

- ក្នុងករណីទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ វិជ្ជមាន ត្រូវយកសំណាកធ្វើតេស្ត PCR បញ្ជាក់ និងធ្វើ Sequencing រកប្រភេទវីរុស ព្រមទាំងត្រូវស្នាក់នៅដាច់ដោយឡែក ដោយអនុវត្តដូចខាងក្រោម៖

១-សម្រាប់ជនបរទេសទាំងអស់ដែលចូលមកព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យព្យាបាលនៅសណ្ឋាគារ ឬនិវេសនដ្ឋានរបស់ស្ថានទូត ឬទីកន្លែងដែលពួកគាត់ជ្រើសរើស ដោយពុំចាំបាច់ទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ របស់រដ្ឋទេ។

២-សម្រាប់ជនជាតិខ្មែរ ទាំងអ្នកមកពីបរទេស និងអ្នកនៅក្នុងប្រទេស អនុញ្ញាតឱ្យស្នាក់នៅព្យាបាលតាមផ្ទះ ដូចករណីអ្នកជំងឺកូវីដ-១៩ ប្រភេទអាល់ហ្វា ឬដែលតា ដែរ ដោយគោរពតាមនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ។ ប្រសិនបើមានកត្តាហានិភ័យសុខភាព អ្នកជំងឺអាចធ្វើការជ្រើសរើសធ្វើការព្យាបាលនៅមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ រដ្ឋ ឬឯកជន ដែលទទួលបានការអនុញ្ញាតឱ្យព្យាបាលជំងឺកូវីដ-១៩។

៣- ចំពោះអ្នកជំងឺកូវីដ-១៩ ប្រភេទអូមីក្រុង ជាជនបរទេស ឬជនជាតិខ្មែរ ដែលកំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ប្រសិនជាមានបំណងចាកចេញទៅព្យាបាល



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

នៅតាមផ្ទះ ឬសណ្ឋាគារ ត្រូវបានអនុញ្ញាតឱ្យចាកចេញចាប់ពីយប់ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ នេះតទៅ។ ក្នុងករណីដែលអ្នកជំងឺមានគេហដ្ឋានសមរម្យ អាចស្នាក់នៅព្យាបាលដាច់ដោយឡែកពីក្រុមគ្រួសារ និងត្រូវគោរពតាមនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ ដោយមានការចូលរួមសហការរាយការណ៍ជូនដល់អាជ្ញាធរមូលដ្ឋាន។

សេចក្តីប្រកាសព័ត៌មាននេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ ៤រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- គណៈប្រចាំការ នៃ គ.ប.ក.
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ
- អនុគណៈកម្មការគ្រប់គ្រងច្រកចេញចូលប្រទេស និងការធ្វើចត្តាឡីស័ក
- ឯកសារ កាលប្បវត្តិ